# សេចក្តីថ្លែងការណ៍ និងសំណើរបស់អង្គការអភិរក្សអន្តរជាតិនានា ក្នុងវេទិកាជាតិស្តីពីការ ការពារ និងការអភិរក្សធនធានធម្មជាតិ

ខ្ញុំបាទសូមគោរព**សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ។

ខ្ញុំបាទសូមគោរពសម្តេច ឯកឧត្តម លោកជំទាវ លោកឧញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ជាទីគោរពដ៏ខ្ពង់ខ្ពស់ និងជាទីរាប់អាន។

ខ្ញុំបាទឈ្មោះ **សេង ទៀក** ជានាយកអង្គការ WWF កម្ពុជា និងជាអ្នកតំណាងឲ្យអង្គការក្រៅរដ្ឋាភិបាលអភិរក្សអន្តរជាតិចំនួន៧រួមមាន ៖ អង្គការ BirdLife International, អង្គការ Conservation International, អង្គការ Flora Fauna International, អង្គការ Wildlife Alliance, អង្គការ Wild Earth Allies, អង្គការ Wildlife Conservation Society and អង្គការ World Wide Fund For Nature (WWF) មានកិត្តិយដ៏ធំធេងដែលបានអនុញ្ញាត្តិឲ្យចូលរួម និងលើកជាយោបល់ជម្រាប ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងវេទិកាជាតិស្តីពីការការពារ និងការអភិរក្សធនធានធម្មជាតិ នាថ្ងៃនេះ។

ជាបឋម យើងខ្ញុំទាំងអស់គ្នា សូមចូលរួមអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជាដែល នាពេលកន្លងទៅថ្មីៗនេះ បានកំណត់ និងចាត់បញ្ចូលតំបន់ព្រៃឈើធម្មជាតិ និងតំបន់របៀងសត្វព្រៃមួយចំនួនធំឲ្យទៅជា តំបន់ការពារធម្មជាតិស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងបរិស្ថាន។ បច្ចុប្បន្ននេះទំហំផ្ទៃដីតំបន់ការពារធម្មជាតិនិងតំបន់របៀងសត្វព្រៃសរុបមាន៧.៤៣លានហិតាជិតស្មើ និងពាក់កណ្តាលនៃផ្ទៃប្រទេសទាំងមូល ។

យើងខ្ញុំក៏ សូមចូលរួមអបអរសាទរផងដែរដល់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការសម្រេច និងរក្សាបានកំណើនលូតលាស់សេដ្ឋកិច្ចជាតិខ្ពស់ គឺគិតជាមធ្យម ៧% ក្នុងមួយឆ្នាំៗ រយៈពេល ១០ ឆ្នាំ ជាប់ៗគ្នាកន្លងមកនេះ។ យើងខ្ញុំទទួលស្គាល់ថា ធនធានធម្មជាតិ និងប្រពន្ធ័អេកូឡូស៊ី គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិ ។

យើងខ្ញុំទទួលស្គាល់ថាវិស័យទេសចរណ៍តាមរយៈអេកូទេសចរណ៍ឬទេសចរណ៍ធម្មជាតិ មានការរីកចម្រើនលឿនបំផុតនៅក្នុងពិភពលោក។ ទេសចរណ៍មើលសត្វព្រៃពិសេសសត្វខ្លាដំបងផ្តល់ចំណូលរាប់លានដុល្លាអាមេរិកដល់សេដ្ឋកិច្ចជាតិ និងបង្កើតការងាររាប់ពាន់កន្លែងផងដែរដល់សហគមន៍មូលដ្ឋាន។ តំបន់ភាគឥសាន្តនៃប្រទេសកម្ពុជា ដែលរាជរដ្ឋាភិបាលបានកំណត់រួចហើយថាជាប៉ូលទេសចរណ៍ទី៣ នៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈអំណោយផលដ៏ប្រសើរ និងមានសក្តានុពលយ៉ាងធំធេង សម្រាប់ការអភិវឌ្ឍទេសចរណ៍មើលសត្វព្រៃនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍យើងនេះ។ ខ្លាដំបងគឺជាសត្វ ដែលគេស្រឡាញ់ និងមានការទាក់ទាញជាងគេនៅលើភពផែនដីយើងនេះ ។ អភិរក្សសត្វខ្លាដំបងបាន មានន័យថាយើង ការពារព្រៃឈើ តំបន់វាលស្មៅធម្មជាតិ ប្រភពទឹក និងសត្វព្រៃជាច្រើនប្រភេទដែលជាចំណីរបស់វា ។

*សំណួរទី១ របស់ខ្ញុំបាទ ចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រី៖*
*តើសម្តេចតេជោនាយករដ្ឋមន្ត្រី អាចប្រកាសគាំទ្រឲ្យមានការអនុវត្តគម្រោងស្តារពូជខ្លាដំបងឡើងវិញនៅក្នុងដែនជម្រកសត្វព្រៃស្រែពកនៅខេត្តមណ្ឌលគីរី បានដែរឬទេ ? ព្រោះសត្វខ្លាដំបងនេះនឹងក្លាយជាផលិតផលទេសចរធម្មជាតិថ្មីមួយ សម្រាប់ប្រទេសកម្ពុជានៅពេលដ៏ខ្លីខាងមុខ ។*

យើងខ្ញុំកត់សំគាល់ថា កាតួកិច្ច តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន មានទំហំមហាសាលប៉ុន្តែសមត្ថភាព និងធនធានរបស់ក្រសួងដើម្បីអនុវត្តការងារដ៏ធំធេងនេះគឺនៅមានកំរិតនៅឡើយ។ ថវិកាជាតិសម្រាប់ក្រសួងបរិស្ថានក្នុងឆ្នាំ ២០១៧ មានប្រហែល 0.៤% នៃខ្ទង់ថវិកាជាតិប្រចាំឆ្នាំ(គឺប្រហែល ២០លានដុល្លាសម្រាប់ឆ្នាំ ២០១៧)។ ចំនួនថវិកានេះគឺ នៅមិនគ្រប់គ្រាន់ទេ សម្រាប់ការគ្រប់គ្រងឲ្យមានប្រសិទ្ធភាពលើតំបន់ការពារធម្មជាតិ ៤៦ កន្លែង និងតំបន់របៀងសត្វព្រៃជាង១.៤ លាន ហិតា។

*សំណួរទី២ របស់ខ្ញុំបាទ ចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រី៖*
*តើសម្តេចតេជោនាយករដ្ឋមន្ត្រី អាចបង្កើនថវិកាជាតិសម្រាប់ក្រសួងបរិស្ថានពី បច្ចុប្បន្ន 0.៤% ដល់ ២% នៃខ្ទង់ថវិកាជាតិប្រចាំឆ្នាំបានដែរឬទេ ដែលក្នុងនោះ ១% នៃខ្ទង់ថវិការនេះគឺ សម្រាប់ការចំណាយផ្ទាល់ដល់តំបន់ការពារធម្មជាតិ និងតំបន់របៀងសត្វព្រៃ ?*

យើងខ្ញុំទទួលស្គាល់ពីភាពចាំបាច់សម្រាប់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនៅកម្ពុជា។ ការធ្វើឲ្យមានតុល្យភាពរវាងការប្រើប្រាស់ធនធានធម្មជាតិនិងការអភិរក្សគឺជាកត្តាចម្បងសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពរបស់ប្រទេសកម្ពុជា។ ចំណុចសំខាន់១ ដើម្បីធានាតុល្យភាពនេះគឺការរៀបចំផែនការប្រើប្រាស់ដីធ្លីកម្រិតថ្នាក់ខេត្តដែលយកតំបន់ការពារធម្មជាតិ មាន

ក្នុងខេត្ត និងតំបន់របៀងសត្វព្រៃ ជាចំណុចគោល សម្រាប់ការរៀបចំផែនប្រើប្រាស់ដីធ្លីនេះ។ ផែនការប្រើប្រាស់ដីធ្លី អាចទាក់ទាញអ្នកពាក់ពន្ធ័នានាធ្វើការរួមគ្នាដើម្បីសម្រេចកម្មវិធីសមាហរណកម្មអភិវឌ្ឍន៍ និងអភិរក្សឲ្យមាននិរន្តភាពបាន ។

*សំណួរទី៣ របស់ខ្ញុំបាទ ចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រីៈ*
*តើសម្តេចតេជោនាយករដ្ឋមន្ត្រី អាចប្រកាសគាំទ្រឲ្យមានការរៀបចំផែនការប្រើប្រាស់កម្រិតថ្នាក់ខេត្ត ពិសេសសម្រាប់ខេត្តដែលសម្បូរធនធានធម្មជាតិ បានដែរ ឬទេ?*

ជាទីបញ្ចប់នេះ ខ្ញុំបាទនិងយើងខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចអគ្គសេនាបតីតេជោនាយករដ្ឋមន្ត្រីដែលបានរៀបចំវេទិការជាតិស្តីពីការ ការពារ និងអភិរក្សធនធានធម្មជាតិដ៏មានសារសំខាន់នេះឡើងដើម្បីឲ្យអ្នកពាក់ពន្ធ័នានាបានលើកឡើងពីកង្វល់ និងគំនិតនានាសំដៅធ្វើការរួមគ្នា លើការពារធនធានធម្មជាតិរបស់ប្រទេសកម្ពុជាយើង ។

សូមគោរពជូនពរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្តេច ឯកឧត្តម លោកជំទាវ លោកឧញ៉ា លោក លោកស្រី ភ្ញៀវកិត្តយសជាតិ និងអន្តរជាតិទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ ។ សូមអគុណ